ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៩ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៥០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩១៣ /៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /១២១៣ /១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការប្រែប្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- តាមសំណើរបស់ក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវទីតាំងដូចខាងក្រោម÷

-ដីត្រពាំងត្រាវ ស្ថិតនៅសង្កាត់កំពង់ក្របៅ និងសង្កាត់ព្រៃតាហ៊ូ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ មានទំហំសរុប២៧.២២០ម៉ែត្រក្រឡា។

-ដីបឹងភេ ស្ថិតនៅសង្កាត់កំពង់ក្របៅ សង្កាត់អាចារ្យលាក់ និងសង្កាត់ព្រៃតាហ៊ូ ក្រុងស្ទឹងសែន ខេត្តកំពង់ធំមានទំហំសរុប ២៩,៧៦ហិកតា។

**មាត្រា ២ :-**

-ការលុបទីតាំងដូចមានចែងក្នុងមាត្រា១ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីដោយក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាលាខេត្តកំពង់ធំ។

**មាត្រា ៣ :-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៧១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល។

**សម្រេច**

**មាត្រា១:** ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ជូនក្រសួងមហាផ្ទៃ ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោមនេះ÷

ឯកតា:លានរៀល

| ជំពូក | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | ឥណទានក្រោយនិយ័តកម្មលើកទី១ | និយ័តកម្ម | | ឥណទានថ្មី |
|---|---|---|---|---|---|---|
| | | | | កើន | ថយ | |
| | **និយ័តកម្មចេញ** | | | | | |
| ២១ | ៩៩- ចំណាយមិនទាន់បែងចែក ឥណទានវិលស់បំណុល អចលកម្មប៊ី | ២០០ ០០០ | ១៤៦ ៥៦៥ | | ១០១ ២០០ | ៤៥ ៣៦៥ |
| | **និយ័តកម្មចូល** | | | | | |
| ២១ | ០៧.១-ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ អចលកម្មប៊ី | ២៣ ៦០០ | ៥៦ ៦០០ | ៤ ២០០ | | ៦០ ៨០០ |
| ២១ | ២០- ក្រសួងអភិវឌ្ឍន៍ជនបទ អចលកម្មប៊ី | ១៤០ ០០០ | ១៤០ ០០០ | ៣៥ ០០០ | | ១៧៥ ០០០ |
| ២១ | ២៥- ក្រសួងសាធារណការនិងដឹកជញ្ជូន អចលកម្មប៊ី | ៤៦០ ០០០ | ៤៨០ ៤៣៥ | ៦២ ០០០ | | ៥៤២ ៤៣៥ |

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និង រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន សម្តេចអគ្គមហាសេនាបតីតេជោ

នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦៦៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការធ្វើអនុបយោគ ឬចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការប្រែប្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០៦ /៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធី នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- តាមសំណើ របស់សាលារាជធានីភ្នំពេញ

## សម្រេច

**មាត្រា ១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវទីតាំងខាងក្រោមសួនច្បារសាធារណៈ ខាងជើងផ្សារចាស់ ត្រង់ចន្លោះផ្លូវលេខ ១០៦ និងផ្លូវលេខ ១០៨ ស្ថិតនៅសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដែលមានប្លង់ដីទីតាំង G ទំហំ ៩.១៣៧,៤៧ (ប្រាំបួនពាន់ មួយរយសាមសិបប្រាំពីរ ក្បៀសសែសិបប្រាំពីរ) ម៉ែត្រក្រឡា ។

**មាត្រា២.-**

ត្រូវបានចាត់ចែង និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋដូចមានចែងក្នុងមាត្រា១ នៃអនុក្រឹត្យនេះ ស្របតាមលក្ខខណ្ឌដូចខាងក្រោម÷

-ត្រូវដំណើរការដាក់ជួល ស្របតាមនីតិវិធី និងបទប្បញ្ញត្តិជាធរមាន

-ការអភិវឌ្ឍទីតាំងដូចមានចែងក្នុងប្រការ១ ត្រូវដំណើការ ស្របតាមបទប្បញ្ញត្តិជាធរមាន

-ការជួលទ្រព្យសម្បត្តិរដ្ឋនេះ មិនត្រូវធ្វើឱ្យផ្លាស់ប្តូរមុខងារបម្រើសេវាសាធារណៈ នៃទ្រព្យសម្បត្តិរដ្ឋ ដែលស្ថិតនៅទីតាំងផ្នែកខាងលើឡើយ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧២៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០១៧

## រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/ ០៨០៥/៣៩៤ ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ទៅជា គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

-យោងអនុក្រឹត្យលេខ ១៣៧អនក្រ.បក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាល ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០១៦

-បានឃើញ អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់ពេលវេលាបម្រើការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា

-បានឃើញ អនុក្រឹត្យលេខ ២៥ អនក្រ/បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

-តាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

# ស ម្រេ ច

**<u>មាត្រា ១</u>.-**

ត្រូវបានអនុញ្ញាតឱ្យមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជា បានឈប់សម្រាកការងារ ឆ្នាំ២០១៧ តាមប្រតិទិន ដូចខាងក្រោម :

| | | | |
|---|---|---|---|
| - ថ្ងៃទី ០១ | មករា | ទិវាចូលឆ្នាំសកល | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៧ | មករា | ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១១ | កុម្ភៈ | ពិធីបុណ្យមាឃបូជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៨ | មីនា | ទិវាអន្តរជាតិនារី | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៤-១៥-១៦ | មេសា | ពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំរកា | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ០១ | ឧសភា | ទិវាពលកម្មអន្តរជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១០ | ឧសភា | ពិធីបុណ្យវិសាខបូជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៣-១៤-១៥ | ឧសភា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ១៤ | ឧសភា | ព្រះរាជពិធីច្រត់ព្រះនង្គ័ល | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០១ | មិថុនា | ទិវាកុមារអន្តរជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៨ | មិថុនា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា នរោត្តម មុនិនាថ សីហនុ** | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៩-២០-២១ | កញ្ញា | ពិធីបុណ្យភ្ជុំបិណ្ឌ | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ២៤ | កញ្ញា | ទិវាប្រកាសរដ្ឋធម្មនុញ្ញ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៥ | តុលា | ទិវាប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ២៣ | តុលា | ទិវារំលឹកខួបនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ២៩ | តុលា | ព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិរបស់ **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០២-០៣-០៤ | វិច្ឆិកា | ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និង សំពះព្រះខែ អកអំបុក | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ០៩ | វិច្ឆិកា | ពិធីបុណ្យឯករាជ្យជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១០ | ធ្នូ | ទិវាសិទ្ធិមនុស្សអន្តរជាតិ | សម្រាក ០១ ថ្ងៃ |

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាល នៃគណៈអភិបាលរាជធានី និងខេត្ត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៣
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ២០អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងនាយកដ្ឋាន/ ...

ផែនការនិងស្ថិតិនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី២

## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២ .-**

អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វមានតួនាទីជាសេនាធិការឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលើការងារសុខភាពសត្វនិងផលិតកម្មសត្វ និងមានភារកិច្ចដូចតទៅ៖

- គ្រប់គ្រង អភិវឌ្ឍ ត្រួតពិនិត្យ តាមដាន និងវាយតម្លៃអនាម័យ សុខុមាលភាព ទាក់ទងនឹងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- ជំរុញការចិញ្ចឹមសត្វនិងធានានិរន្តរភាពនៃការផ្គត់ផ្គង់សត្វនិងផលិតផលសត្វប្រកបដោយគុណភាព និងសុវត្ថិភាព តាមរយៈការរៀបចំនិងការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រ លើកកម្ពស់ការស្រាវជ្រាវ បណ្តុះបណ្តាល និងការអភិវឌ្ឍ លើការបង្កាត់ពូជសត្វ ប្រព័ន្ធកសិដ្ឋាន ការគ្រប់គ្រងចំណីសត្វ បសុឱសថ និងសេវាកម្មសុខភាពសត្វ
- រួមចំណែកបង្កើនចំណូលដល់សេដ្ឋកិច្ចជាតិនិងកសិករ តាមរយៈការលើកទឹកចិត្តការវិនិយោគ ការសម្រួលពាណិជ្ជកម្ម ពាក់ព័ន្ធវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- ពង្រឹង ពង្រីកកិច្ចសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិ លើវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- រៀបចំផែនការអភិវឌ្ឍស្តីពីការគ្រប់គ្រងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ ដែលបង្ហាញពីគោល-នយោបាយជាតិ យុទ្ធសាស្ត្រ និងកម្មវិធីអភិវឌ្ឍវិស័យសុខភាពសត្វនិងផលិតកម្មសត្វដោយមានការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់
- រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា សំដៅគ្រប់គ្រងវិស័យសុខភាពសត្វនិងផលិតកម្មសត្វឱ្យមានប្រសិទ្ធភាព

- ជំរុញ គ្រប់គ្រង និងលើកកម្ពស់ផលិតកម្មសត្វ តាមរយៈការបង្កើនផលិតភាព ការលើកកម្ពស់ប្រសិទ្ធភាពសេដ្ឋកិច្ច ការធានាសុខុមាលភាពសត្វ និងការបង្ការហានិភ័យសុខភាពសត្វ សុខភាពសាធារណៈ និងបរិស្ថាន
- គ្រប់គ្រងនិងត្រួតពិនិត្យអនាម័យ ប្រសិទ្ធភាពនិងសុវត្ថិភាពចំណីសត្វ វត្ថុធាតុដើម សារធាតុបន្ថែមសម្រាប់លាយផ្សំចំណីសត្វ និងបសុឱសថ
- គ្រប់គ្រងនិងត្រួតពិនិត្យអនាម័យសត្វ សាច់ ផលិតផលសត្វ អាជីវកម្មពិឃាតសត្វ សត្តឃាតដ្ឋាន កសិដ្ឋានចិញ្ចឹមសត្វនិងកន្លែងបង្កាត់ពូជសត្វ ស្ថានីយចត្តាឡីស័កសត្វ ទីកន្លែង ព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ ទីកន្លែងអាជីវកម្មសត្វ ព្រមទាំងកន្លែងផ្សេងទៀត
- ត្រួតពិនិត្យអនាម័យ វិញ្ញាបនបត្រ ចរាចរណ៍សត្វ និងផលិតផលសត្វ ស្របតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល
- ត្រួតពិនិត្យអនាម័យកន្លែងតាំងលក់សត្វ សាច់ ផលិតផលសត្វដោយសហការជាមួយក្រសួងពាក់ព័ន្ធ
- អង្កេត តាមដាន ស្រាវជ្រាវជំងឺសត្វ ជំងឺស៊ូណូស ការចិញ្ចឹមសត្វ ជ្រើសរើសពូជ និងធ្វើរោគវិនិច្ឆ័យជំងឺសត្វ វាយតម្លៃគុណភាពសុវត្ថិភាពចំណីសត្វនិងបសុឱសថ
- រៀបចំផលិតឯកសារផ្សព្វផ្សាយព័ត៌មាន អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងប្រាស្រ័យទាក់ទងបច្ចេកទេសស្ថានភាពផលិតកម្មនិងតម្រូវការទីផ្សារ លិខិតបទដ្ឋាន កម្មវិធីអភិវឌ្ឍ និងព័ត៌មានផ្សេងទៀតដែលពាក់ព័ន្ធនឹងវិស័យសុខភាពសត្វនិងផលិតកម្មសត្វដល់អ្នកចិញ្ចឹមសត្វ ផ្នែកឯកជន ពាណិជ្ជករ អាជីវករ និងអ្នកពាក់ព័ន្ធវិស័យសុខភាពសត្វនិងផលិតកម្មសត្វ ដើម្បីបង្កើនផលិតភាពគុណភាព ប្រសិទ្ធភាពផលិតកម្មសត្វ ផលិតផលសត្វ និងការធ្វើពាណិជ្ជកម្ម
- ធ្វើសហប្រតិបត្តិការជាមួយអង្គភាពនិងស្ថាប័នពាក់ព័ន្ធ ផ្នែកឯកជន ដៃគូអភិវឌ្ឍ សហគមន៍ សមាគម អង្គការជាតិ និងអង្គការអន្តរជាតិនានាទាក់ទងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- ធ្វើអធិការកិច្ចលើរាល់សកម្មភាពពាក់ព័ន្ធវិស័យសុខភាពសត្វនិងផលិតកម្មសត្វ និងជំរុញការអនុវត្តច្បាប់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រគល់ជូន។

អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ ដឹកនាំដោយអគ្គនាយក១រូប និងអគ្គនាយករងមួយចំនួនស្របតាមអនុក្រឹត្យលេខ១១៤អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

**មាត្រា៣ .-**

រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ មាននាយកដ្ឋានចំនួន៤ និងវិទ្យាស្ថានចំនួន១ ដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការ
- នាយកដ្ឋានផលិតកម្មសត្វ
- នាយកដ្ឋានសុខភាពសត្វនិងសុខភាពសាធារណៈបសុព្យាបាល/

- នាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេសនិងនីតិកម្ម
- វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វនិងផលិតកម្មសត្វ

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធាននាយកដ្ឋាន១រូប និងអនុប្រធាននាយកដ្ឋានមួយចំនួនស្រប តាមអនុក្រឹត្យលេខ១១៤អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិង មុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ ដឹកនាំដោយនាយក១រូប ឋានៈស្មើប្រធាន នាយកដ្ឋាន និងនាយករងមួយចំនួន ឋានៈស្មើអនុប្រធាននាយកដ្ឋាន ស្របតាមអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធ គ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

អង្គការលេខរបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៤ .-**

នាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកា និងការងារទូទៅរបស់នាយកដ្ឋាន
- គ្រប់គ្រងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ ដោយរាប់ទាំងការគ្រប់គ្រង ស្ថិតិមន្ត្រី ចូលរួមត្រួតពិនិត្យ វាយតម្លៃលទ្ធផលការងារ លើកសំណើតែងតាំង ផ្ទេរភារកិច្ច លើក សរសើរឬដាក់ពិន័យ រៀបចំគោលនយោបាយពាក់ព័ន្ធនឹងក្របខណ្ឌបៀវត្ស ប្រាក់កម្រៃ និងរបបឧបត្ថម្ភ ផ្សេងៗ
- គ្រប់គ្រងកិច្ចការរដ្ឋបាលទូទៅ សណ្តាប់ធ្នាប់ សន្តិសុខ ពិធីការ ក្នុងអគ្គនាយកដ្ឋានសុខភាពសត្វនិង ផលិតកម្មសត្វ
- សម្របសម្រួលនិងទំនាក់ទំនងការងាររដ្ឋបាល ការងារសាធារណៈ ផ្លាស់ប្តូរព័ត៌មាន ការងារសហ-ប្រតិបត្តិការជាមួយអង្គភាព ស្ថាប័ន ផ្នែកឯកជន អង្គការជាតិ អង្គការអន្តរជាតិ ភ្នាក់ងារ និងបណ្តា ប្រទេសនានា
- រៀបចំផែនការអភិវឌ្ឍន៍ធនធានមនុស្សនិងបណ្តុះបណ្តាលដល់មន្ត្រីអគ្គនាយកដ្ឋានសុខភាពសត្វនិង ផលិតកម្មសត្វ និងអ្នកពាក់ព័ន្ធលើការងារផែនការ គណនេយ្យ និងហិរញ្ញវត្ថុ ការលើកថវិកាតាមកម្មវិធី អនុកម្មវិធី និងគម្រោង នីតិវិធីចំណាយនិងការទូទាត់ និងជំរុញលើកទឹកចិត្តឱ្យមានសមត្ថភាពនិង សមធម៌យេនឌ័រ
- គ្រប់គ្រងការទទួល ការបញ្ជូន និងបែងចែកលិខិត ការចេញលិខិតឧទ្ទេសនាម លិខិតបញ្ជាបេសកកម្ម
- រៀបចំធ្វើរបាយការណ៍ការងារនិងសកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្ម សត្វ
- ជំរុញ សម្របសម្រួលរៀបចំគោលនយោបាយជាតិ យុទ្ធសាស្ត្រ ផែនការអភិវឌ្ឍវិស័យសុខភាព សត្វនិង ផលិតកម្មសត្វ ផែនការថវិកាកម្មវិធីនិងអនុកម្មវិធី និងផែនការសកម្មភាពរបស់អគ្គនាយកដ្ឋាន សុខភាព សត្វនិងផលិតកម្មសត្វ

- ប្រមូលទិន្នន័យ ព័ត៌មាន ស្ថិតិ និងវិភាគលើវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- ទទួលខុសត្រូវលើការងាររៀបចំនិងតាមដានការអនុវត្តថវិកា
- ទទួលខុសត្រូវគ្រប់គ្រងពាក់ព័ន្ធការងារគណនេយ្យនិងហិរញ្ញវត្ថុ ការងារលទ្ធកម្មសាធារណៈ ការទទួលរក្សានិងគ្រប់គ្រងឧបករណ៍ សម្ភារៈ បរិក្ខារ ទ្រព្យសម្បត្តិផ្សេងៗ គ្រប់គ្រងអចលនទ្រព្យនិងធ្វើបញ្ជីសារពើភណ្ឌរបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- វិភាគ ផ្តល់យោបល់ និងរៀបចំគម្រោងវិនិយោគសាធារណៈនិងវិនិយោគឯកជនក្នុងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- គ្រប់គ្រងការប្រមូលចំណូលនិងចំណាយគ្រប់ប្រភេទរបស់អគ្គនាយកដ្ឋានត្រូវអនុវត្តតាមនីតិវិធីហិរញ្ញវត្ថុសាធារណៈ
- គ្រប់គ្រងការងារសហប្រតិបត្តិការអន្តរជាតិ ទំនាក់ទំនងសម្របសម្រួលរៀបចំគម្រោងកិច្ចសហប្រតិបត្តិ-ការអន្តរជាតិជាមួយអង្គការជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានា
- តាមដាន ជំរុញ និងវាយតម្លៃការអនុវត្តគម្រោងថវិកាតាមកម្មវិធី អនុកម្មវិធីនិងគម្រោងសហប្រតិបត្តិការរៀបចំកំណត់ហេតុកិច្ចប្រជុំ រៀបចំអនុស្សរណៈយោគយល់គ្នា ពិធីសារ អនុសញ្ញា និងកិច្ចព្រមព្រៀងនានាទាក់ទងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- រៀបចំកិច្ចប្រជុំ សិក្ខាសាលានិងផ្សព្វផ្សាយដល់អង្គភាពសុខភាពសត្វនិងផលិតកម្មសត្វ វិស័យឯកជនអង្គការជាតិនិងអង្គការអន្តរជាតិ ភ្នាក់ងារផ្តល់ជំនួយផ្សេងៗ អ្នកពាក់ព័ន្ធផ្សេងៗ អំពីគោលនយោបាយជាតិ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានប្រគល់ជូន។

**មាត្រា៥ .-**

នាយកដ្ឋានផលិតកម្មសត្វ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកា និងការងារទូទៅរបស់នាយកដ្ឋាន
- រៀបចំផែនការផលិតកម្មសត្វឱ្យស្របតាមគោលនយោបាយនិងទីផ្សារតម្រូវ សិក្សាស្រាវជ្រាវពី សក្តានុពលសេចក្តីត្រូវការ ការផ្គត់ផ្គង់សត្វនិងផលិតផលសត្វ
- គ្រប់គ្រង ត្រួតពិនិត្យ តាមដាន វាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមនិងបំប៉នសត្វ ទីកន្លែងបង្កាត់ពូជសត្វ
- ត្រួតពិនិត្យ តាមដាន វាយតម្លៃទីកន្លែងផលិតនិងលាយផ្សំចំណីសត្វ
- គ្រប់គ្រង អភិរក្ស អភិវឌ្ឍធនធានសេនេទិចសត្វ និងធ្វើបញ្ជីពូជសត្វ
- ប្រមូល វិភាគចងក្រងទិន្នន័យ ជំរឿន ស្រង់ស្ថិតិសត្វគ្រប់ប្រភេទ ស្ថិតិកសិដ្ឋានចិញ្ចឹមសត្វ ស្ថិតិកន្លែងបង្កាត់ពូជសត្វ ស្ថិតិកន្លែងផលិត លាយផ្សំចំណីសត្វ កន្លែងលក់ចំណីសត្វ និងមន្ទីរពិសោធន៍វិភាគចំណីសត្វ
- រៀបចំធ្វើអត្តសញ្ញាណកម្មសត្វ ប្រព័ន្ធតាមដានសត្វនិងផលិតផលសត្វ

- គ្រប់គ្រងកាកសំណល់សត្វ គ្រប់គ្រងការងារឡជីវឧស្ម័ន តាមដាននិងវាយតម្លៃផលប៉ះពាល់បណ្តាលពីផលិតកម្មសត្វ
- គ្រប់គ្រងផលិតកម្មចំណីសត្វ អនុវត្តបង្ហាញនិងផ្សព្វផ្សាយចំណីសត្វ បច្ចេកទេសផ្សំចំណីសត្វ រៀបចំបមាណីយចំណីសត្វ និងត្រួតពិនិត្យគុណភាព ការវេចខ្ចប់ និងស្លាកសញ្ញាព័ត៌មានចំណីសត្វ វត្ថុធាតុដើមសម្រាប់លាយផ្សំចំណីសត្វ និងសារធាតុបន្ថែមសម្រាប់លាយផ្សំចំណីសត្វ
- តាមដាននិងវិភាគទិន្នន័យតម្លៃសត្វ សាច់ ផលិតផលសត្វ ចំណីសត្វ វត្ថុធាតុដើមសម្រាប់ចំណីសត្វ និងសារធាតុបន្ថែមសម្រាប់ចំណីសត្វ ព្រមទាំងសម្ភារៈបម្រើការចិញ្ចឹមសត្វ
- ចូលរួមពិសោធស្រាវជ្រាវនិងផ្សព្វផ្សាយលើការចិញ្ចឹមសត្វ  ការបង្កាត់ពូជសត្វតាមបច្ចេកវិទ្យាទំនើប ការធ្វើបង្ហាញលើការចិញ្ចឹមសត្វ បច្ចេកទេសផលិត លាយផ្សំចំណីសត្វនិងដំណាំចំណីសត្វ
- បណ្តុះបណ្តាលបច្ចេកទេសផលិតកម្មសត្វដល់អ្នកពាក់ព័ន្ធ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានប្រគល់ជូន។

**មាត្រា៦ .-**

នាយកដ្ឋានសុខភាពសត្វនិងសុខភាពសាធារណៈបសុព្យាបាល មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកា និងការងារទូទៅរបស់នាយកដ្ឋាន
- រៀបចំផែនការយុទ្ធសាស្ត្រស្តីពីសុខភាពសត្វនិងជំងឺស៊ូណូស
- ត្រួតពិនិត្យអនាម័យសត្វ ផលិតផលសត្វ បសុឱសថ និងចំណីសត្វ
- គ្រប់គ្រងសត្តឃាតដ្ឋាន អាជីវកម្មពិឃាតសត្វ ត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន និងត្រួតពិនិត្យអនាម័យសត្វ សាច់ ផលិតផលសត្វនៅសត្តឃាតដ្ឋាននិងទីកន្លែងតាំងលក់
- គ្រប់គ្រង ពង្រឹង សម្របសម្រួលនិងធ្វើឱ្យប្រសើរឡើងនូវសេវាកម្មបសុព្យាបាលនិងសេវាសុខភាពសាធារណៈបសុព្យាបាល
- ត្រួតពិនិត្យ តាមដាន វាយការណ៍ស្ថានភាពសុខភាពសត្វ ស្ថានភាពជំងឺស៊ូណូស និងចាត់វិធានការបសុព្យាបាលដើម្បីបង្ការ ទប់ស្កាត់ ករណីមានផ្ទុះជំងឺឆ្លងរាលដាលនិងកំណត់ផែនទីតំបន់ផ្ទុះជំងឺឆ្លងសត្វ និងជំងឺស៊ូណូស
- តាមដាន ពិនិត្យ ជំរុញការចាក់ថ្នាំការពារជំងឺឆ្លងសត្វ និងអន្តរាគមន៍ចាក់ថ្នាំការពារ ពិនិត្យនិងព្យាបាលជំងឺសត្វ
- ត្រួតពិនិត្យ តាមដាន វាយតម្លៃអនាម័យសត្វនិងផលិតផលសត្វ នៅទីកន្លែងចិញ្ចឹមសត្វ កសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងបង្កាត់ពូជសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ ស្ថានីយចត្តាឡីស័កសត្វនិងផលិតផលសត្វ ទីកន្លែងកែច្នៃផលិតផលសត្វ ទីកន្លែងអាជីវកម្មសត្វ មន្ទីរព្យាបាលសត្វ ទីកន្លែងព្យាបាលសត្វ
- គ្រប់គ្រង ត្រួតពិនិត្យគុណភាព ប្រសិទ្ធភាព សុវត្ថិភាព ការធ្វើពាណិជ្ជកម្ម អាជីវកម្មលក់ដូរ និងការតាំងលក់បសុឱសថ ការផលិត លាយផ្សំ ការប្រើប្រាស់បសុឱសថ សម្ភារៈបរិក្ខារបសុព្យាបាល
- គ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃទីកន្លែងពិនិត្យព្យាបាលសត្វនិងមន្ទីរព្យាបាលសត្វ

- រៀបចំបទដ្ឋានគតិយុត្ត សេចក្តីណែនាំ គោលការណ៍ណែនាំ បទបញ្ជា អនុសាសន៍ទាក់ទងសុខភាពសត្វ ជំងឺសត្វ ជំងឺស៊ូណូស វិធានការបសុព្យាបាលនិងវិធានការការពារជំងឺសត្វ និងជំងឺស៊ូណូស
- រៀបចំប្រកាសស្តីពីតំបន់ផ្ទុះជំងឺឆ្លងសត្វ តំបន់ផ្ទុះជំងឺស៊ូណូស និងកំណត់ផែនទីតំបន់ផ្ទុះជំងឺទាំងនេះ
- រៀបចំបទដ្ឋានបច្ចេកទេសសុខុមាលភាពសត្វ ជំរុញសកម្មភាពអប់រំនិងផ្សព្វផ្សាយស្តីពីការបង្ការនិងទប់ស្កាត់អំពើទារុណកម្មលើសត្វ និងគ្រប់គ្រង ត្រួតពិនិត្យ តាមដាននិងវាយតម្លៃការអនុវត្តបទដ្ឋានបច្ចេកទេសសុខុមាលភាពសត្វ
- រៀបចំបទដ្ឋានគតិយុត្ត សេចក្តីណែនាំ គោលការណ៍ណែនាំ បទបញ្ជា អនុសាសន៍ទាក់ទងបច្ចេកទេស និងការរៀបចំចងក្រងឯកសារស្តីពីនីតិវិធី បែបបទសម្រាប់ការនាំចេញ ការនាំចូល ការនាំឆ្លងកាត់ចរាចរក្នុងផ្ទៃប្រទេសនូវសត្វ ផលិតផលសត្វ ចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែមផ្សំចំណីសត្វ បសុឱសថនិងសារធាតុសកម្មសម្រាប់ផលិតបសុឱសថ
- សហការរៀបចំ បណ្តុះបណ្តាល ត្រួតពិនិត្យវាយតម្លៃកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោលនិងភ្នាក់ងារសុខភាពសត្វភូមិ និងចុះបញ្ជី គ្រប់គ្រងនិងធ្វើបច្ចុប្បន្នកម្មគ្រូបង្គោលនិងភ្នាក់ងារសុខភាពសត្វភូមិ
- សហការរៀបចំ ចងក្រងឯកសារបច្ចេកទេសស្តីពីជំងឺសត្វ ជំងឺស៊ូណូស វិធានការការពារនិងការពិនិត្យព្យាបាលសត្វ អនាម័យម្ហូបអាហារមានដើមកំណើតពីសត្វ និងវិធានការការពារ
- បណ្តុះបណ្តាលបច្ចេកទេសទាក់ទងនឹងសុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាលដល់អ្នកពាក់ព័ន្ធ
- សហការជាមួយស្ថាប័ន អង្គការជាតិ និងអង្គការអន្តរជាតិលើការអង្កេត តាមដាន ស្រាវជ្រាវ ការចែករំលែកព័ត៌មានស្តីពីការបង្ការ ទប់ស្កាត់ និងចាត់វិធានការប្រយុទ្ធប្រឆាំងជំងឺសត្វ និងជំងឺស៊ូណូស
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានប្រគល់ជូន។

**មាត្រា៧ .-**

នាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកា និងការងារទូទៅរបស់នាយកដ្ឋាន
- សិក្សា ស្រាវជ្រាវ រៀបចំបទដ្ឋានគតិយុត្ត និងបមាណីយនានាក្នុងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- សហការផ្សព្វផ្សាយបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- សហការវិភាគផ្សព្វផ្សាយព័ត៌មានទីផ្សារ តម្រូវការ ការផ្គត់ផ្គង់ និងតម្លៃសត្វ ផលិតផលសត្វ បសុឱសថ ចំណីសត្វ និងវត្ថុធាតុដើមសម្រាប់លាយផ្សំចំណីសត្វ
- តាមដាន វាយតម្លៃលើការអនុវត្តច្បាប់និងបទដ្ឋានគតិយុត្ត ក្នុងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- តាមដាន ស្រាវជ្រាវ ធ្វើអធិការកិច្ច ចងក្រងសំណុំរឿងបញ្ជូនទៅតុលាការ និងដោះស្រាយបទល្មើសតាមនីតិវិធី
- ធ្វើអន្តរាគមន៍ និងចុះជួយទប់ស្កាត់បទល្មើសទាក់ទងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- ពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ចនៅក្នុងការអនុវត្តច្បាប់ និងដោះស្រាយវិវាទ
- ចុះបញ្ជីបសុឱសថនិងចំណីសត្វ

- ចងក្រង រៀបចំបង្កើត តាមដាន ត្រួតពិនិត្យវាយតម្លៃសហគមន៍ចិញ្ចឹមសត្វ សហគមន៍ភ្នាក់ងារសុខភាពសត្វភូមិ សហគមន៍ និងអង្គការផ្សេងទៀតពាក់ព័ន្ធការងារផលិតកម្មនិងបសុព្យាបាល
- ស្រាវជ្រាវ ប្រមូលផ្តុំ ចងក្រងទិន្នន័យឯកសារ ច្បាប់បទដ្ឋានគតិយុត្តនិងព័ត៌មានផ្សេងៗទាក់ទងវិស័យសុខភាពសត្វនិងផលិតកម្មសត្វសម្រាប់បម្រើការឱ្យការផ្សព្វផ្សាយនិងរក្សាទុកដាក់ឯកសារទាំងនេះ
- រៀបចំសៀវភៅ ឯកសារ អត្ថបទបច្ចេកទេស ទស្សនាវដ្តី និងព្រឹត្តិបត្រព័ត៌មានសម្រាប់ផ្សព្វផ្សាយ
- រៀបចំគេហទំព័រវិស័យសុខភាពសត្វនិងផលិតកម្មសត្វ និងផ្សព្វផ្សាយការងារវិស័យសុខភាពសត្វនិងផលិតកម្មសត្វដល់អ្នកពាក់ព័ន្ធតាមគ្រប់រូបភាព
- គ្រប់គ្រង ត្រួតពិនិត្យ តាមដាននិងវាយតម្លៃការផ្សព្វផ្សាយទាក់ទងវិស័យសុខភាពសត្វនិងផលិតកម្មសត្វនិងសហការអនុវត្តបង្ហាញ
- បណ្តុះបណ្តាល ចងក្រងឯកសារ និងវិធីសាស្ត្រផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានប្រគល់ជូន។

**មាត្រា៨ .-**

វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖
- រៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកា និងការងារទូទៅរបស់វិទ្យាស្ថាន
- រៀបចំផែនការស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ
- អង្កេត តាមដាន ស្រាវជ្រាវជំងឺសត្វ និងស្រាវជ្រាវភាពស៊ាំរបស់មេរោគទៅនឹងបសុឱសថ
- សិក្សាពីការរាលដាលជំងឺសត្វ អេពីដេមីសាស្ត្រ និងវិភាគព័ត៌មានសុខភាពសត្វ
- ធ្វើរោគវិនិច្ឆ័យជំងឺសត្វ
- សិក្សា ពិសោធ ស្រាវជ្រាវលើការងារចិញ្ចឹមសត្វ ការបង្កាត់ពូជសត្វ ចំណីសត្វនិងការផ្តល់ចំណីសត្វ
- សិក្សា ពិសោធ ស្រាវជ្រាវសេនេទិចពូជសត្វ និងការបង្កាត់ពូជសត្វ នៅទីពិសោធន៍
- វិភាគ ពិសោធ ស្រាវជ្រាវគុណភាពចំណីសត្វ វត្ថុធាតុដើមផ្សំចំណីសត្វ សមាសធាតុផ្សំ និងសារធាតុបន្ថែមផ្សេងៗទៀតសម្រាប់ចំណីសត្វ
- វិភាគ ពិសោធ ស្រាវជ្រាវគុណភាពបសុឱសថ វិភាគរកកាកសំណល់បសុឱសថក្នុងផលិតផលសត្វ
- គ្រប់គ្រង ត្រួតពិនិត្យ តាមដាន និងវាយតម្លៃមន្ទីរពិសោធន៍វិភាគចំណីសត្វ
- បណ្តុះបណ្តាលលើការអង្កេតស្រាវជ្រាវជំងឺសត្វនិងការធ្វើរោគវិនិច្ឆ័យជំងឺសត្វ ការងារបច្ចេកទេសពិសោធវិភាគស្រាវជ្រាវលើការងារផលិតកម្មសត្វ
- រៀបចំឯកសារបណ្តុះបណ្តាល វិធីសាស្ត្រអង្កេតស្រាវជ្រាវ ការធ្វើរោគវិនិច្ឆ័យជំងឺសត្វ និងឯកសារទាក់ទងជំងឺសត្វ
- សហការជាមួយមន្ទីរពិសោធន៍នានា អង្គការជាតិ និងអង្គការអន្តរជាតិ លើការងារស្រាវជ្រាវសុខភាពសត្វការងារវិភាគជំងឺសត្វ និងការងារសិក្សាស្រាវជ្រាវផលិតកម្មសត្វ
- ផ្តល់សេវាកម្មបណ្តុះបណ្តាល ពិសោធ ស្រាវជ្រាវពូជសត្វ បង្កាត់ពូជ និងវិភាគចំណីសត្វ វត្ថុធាតុដើមផ្សំចំណីសត្វ សារធាតុផ្សំចំណីសត្វសារធាតុបន្ថែមសម្រាប់ផ្សំចំណីសត្វ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានប្រគល់ជូន។

**មាត្រា៩ .-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនិងអង្គភាពចំណុះនាយកដ្ឋាន និងវិទ្យាស្ថាននៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា១០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ៩ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០០៤ អនក្រ.តត

## អនុក្រឹត្យ

### ស្តីពី

### ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិថ្នាក់វរសេនីយ៍ឯក ជូនលោកវរសេនីយ៍ទោ **គឹម សុផាត** អត្តលេខ២៥៩២៧ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១០០៥ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខដំណែងមន្ត្រីនគរបាលជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពី លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១** : តែងតាំងមុខដំណែង លោកឧត្តមសេនីយ៍ត្រី **លឹម ថាន** អត្តលេខ ០៥៣០៩ ជាជំនួយការ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ដោយមិនយកប្រាក់បៀវត្សរ៍ ។

**មាត្រា ២** : បទបញ្ញត្តទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ តុលា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១០០៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតម្លើងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងព័ត៌មាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តម្លើងថ្នាក់ប្រចាំឆ្នាំ ដល់មន្ត្រីរាជការ ចំនួន ៧៨ រូប ក្នុងឋានន្តរស័ក្តិវរមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព័ត៌មាន ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៦ តទៅ ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១- ឯកឧត្តម **អ៊ីច ផល្លី** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ២- លោកស្រី **តិន ច័ន្ទដា** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ៣- លោក **អ៊ឹម នរិន្ទរិទ្ធ** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ៤- លោក **ប៉ែន សូវៀត** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ៥- លោក **មាស គឹមសួន** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ៦- លោក **រ័ត្ន សុភ័ក្រ** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ៧- លោក **វណ្ណថា វណ្ណរ័ត្ន** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ៨- លោក **សៀង វណ្ណថារ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ៩- ឯកឧត្តម **អ៊ុយ ឃាង** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១០- លោក **អ៊ុក កំពូល** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១១- លោក **ហេង សុមុនី** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១២- លោក **ង៉ែត សៅបូរ័ក្ស** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១៣- លោកស្រី **រស់ កណ្ដាវី** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១៤- លោក **ហង្ស សំរិទ្ធ** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១៥- លោក **ជា សុខេន** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១៦- លោក **ព្រហ្ម សំអឿន** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១៧- លោកស្រី **ខៀវ បុទុម** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១៨- លោក **ឃុត សំខាន់** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១៩- លោក **សុខ នី** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ២០- លោក **ទុំ សុខ** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ២១- ឯកឧត្តម **ជា ក្រូច** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ២២- លោក **សូ សុត្ថា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ២៣- លោក **ពៅ ពិសិដ្ឋ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ២៤- លោកស្រី **កែវ មរកត** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ២៥- លោក **ប៉ែត រស្មី** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ២៦- លោក **លី ចន្ថា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |

| | | |
|---|---|---|
| ២៧- លោក **ជៀង យ៉ារ៉ែត** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ២៨- លោក **ខ្វៃ អាទិត្យា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ២៩- លោក **ភាន់ គុណាសម្បត្តិ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣០- លោក **គួន ខួន** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣១- លោក **មុំ ម៉ាលិកា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣២- លោក **នី ខុឡ្សី** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៣- ឯកឧត្តម **ជា ច័ន្ទបូរិបូរណ៍** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៤- លោក **ឆុន រាសី** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៥- លោក **លន់ ហ្សួរ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៦- លោក **ណុប ម៉ួយ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៧- លោកស្រី **សុខមុំ និមល** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៨- លោកស្រី **ស្វ សុផាវី** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៩- លោកស្រី **រស់ សាឡួន** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤០- លោក **ខាន់ សុភីរម្យ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤១- លោក **យូ សំបូរ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤២- លោក **ម៉ក់ ទិដ្ឋៈ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤៣- លោក **ទឡ្យ សាខន** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤៤- លោក **ជួន ចាន់តារុណា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤៥- លោក **ឡួន សុវណ្ណារិទ្ធ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤៦- លោកស្រី **ពេជ ស៊ីធឿន** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤៧- លោក **សាំ ទូច** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤៨- ឯកឧត្តម **ឃីម រ័ត្ន** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៤៩- ឯកឧត្តម **ត្វូច ណារ័ត្ន** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៥០- ឯកឧត្តម **ចៅ សាខ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៥១- លោក **អនឃួន សំអួន** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៥២- ឯកឧត្តម **ខិន សុភា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៥៣- ឯកឧត្តម **ភខ សារ៉ាត** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៥៤- លោក **ពេជ្រ ភក្តី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៥៥- លោក **ហាស់ សុភ័ក្ត្រ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |

| | | |
|---|---|---|
| ៥៦- លោក **ខឹម ប៉ូរ៉ាណា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៥៧- លោក **នាងនៅ បញ្ញាពិសិដ្ឋ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៥៨- លោក **សាត សុផល** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៥៩- លោក **តោក យ៉ាណា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៦០- លោក **មាស សំអុល** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៦១- លោក **កែ ផុស** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៦២- លោក **អ៊ុក ណាវុធ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៦៣- លោកស្រី **អ៊ុំ វណ្ណៈ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៦៤- លោកស្រី **ប៊ុតផន សុផាណារី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៦៥- លោកស្រី **នង រ័ត្នថា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៦៦- លោក **គឹម សារិន** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៦៧- លោក **អ៊ុំ ឬទ្ធី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៦៨- លោក **គិន វិបុល** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៦៩- លោក **សោម សុផល** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៧០- លោក **អុក ចិន្តា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៧១- លោក **យឹម ប៊ុនថន** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៧២- លោក **ឱ សារឿន** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៧៣- លោកស្រី **ភុល ទូសូភិនី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៧៤- លោកស្រី **នង ឆួក** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៧៥- លោក **សារឹម ប៊ុណ្ណាមី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៧៦- លោក **អ៊ុយ សុធា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៧៧- លោក **ជា ផានិត** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៧៨- លោក **សូ ស៊ីថា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |

**មាត្រា ២ .-** តម្លើងឋានន្តរស័ក្តិប្រចាំឆ្នាំ ដល់មន្ត្រីរាជការ ចំនួន **២៧** រូប ពីឋានន្តរស័ក្តិអនុមន្ត្រី មកឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព័ត៌មាន ចាប់ពីថ្ងៃទី **១៣** ខែ **មេសា** ឆ្នាំ **២០១៦** តទៅ ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១- លោកស្រី **អាំង ចាន់សុធារី** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ២- លោក **អ៊ុន សម័យ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |

| | | |
|---|---|---|
| ៣- លោក **ឈឹម គឹមឈន** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៤- លោក **ចាន់ សូឡី** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៥- លោក **អ៊ុក សុផល** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៦- លោក **ឆុន ទាសនា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៧- លោក **យ៉េង សីហា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៨- លោក **ភូ តុន** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩- លោកស្រី **ខែក ខេមរ៉ាត** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ១០- លោក **អឿង សុខ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ១១- លោក **អៀង គឹមស្រេង** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ១២- លោក **អ៊ុស វិសាល** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ១៣- លោកស្រី **ហួត ដារ៉ូ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ១៤- លោក **កុល ផាន់ណា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ១៥- លោក **អ៊ុក សាផាន** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ១៦- លោក **សាន សុលី** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ១៧- លោក **មុំ ច័ន្ទតារាសូរ្យា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ១៨- លោក **ភ័ណ្ឌ ប៊ុនរិទ្ធ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ១៩- លោក **អ៊ុង ហុងលៀង** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ២០- លោក **ថេង តៃគា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ២១- លោកស្រី **ទឹម សូលីណា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ២២- លោកស្រី **និត្យ កល្យាណី** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ២៣- លោក **ឈន វិបុល** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ២៤- លោកស្រី **ខៀវ ទេពសត្យា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ២៥- លោក **ជា កែវចិន្តា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ២៦- លោក **ហ៊ីល សុតារ៉ា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ២៧- លោក **សួស សុភ័ក្ត្រ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |

**មាត្រា ៣ .-** តម្លើងថ្នាក់ និងតម្លើងឋានន្តរស័ក្តិជាករណីពិសេស ដល់មន្ត្រីរាជការដែលដល់អាយុចូលនិវត្តន៍ ចំនួន ០៤ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព័ត៌មាន ចាប់ពីថ្ងៃទី **១៣ ខែ មេសា ឆ្នាំ ២០១៦** តទៅ ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១- លោកស្រី **សេ សូផាត** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ១ |

២- លោក **ម៉ែន វណ្ណានី** ពីវរមន្ត្រី ថ្នាក់លេខ ៣ មកវរមន្ត្រី ថ្នាក់លេខ ១

៣- លោកស្រី **អ៊ុម ប៉ុណ្ណា** ពីវរមន្ត្រី ថ្នាក់លេខ ៤ មកវរមន្ត្រី ថ្នាក់លេខ ២

៤- លោកជំទាវ **គឹម សុគន្ធាវី** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកវរមន្ត្រី ថ្នាក់លេខ ៣

**មាត្រា ៤ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ មាត្រា២ និងមាត្រា៣ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ច រៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ៩ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .-**

បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនលោក លោកស្រី ជាមន្ត្រីពន្ធនាគារនៃខេត្តកោះកុង ចំនួន ០៩រូប ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចបានល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

**ក- មេដាយមាសការងារ**

១-លោកស្រីវរអគ្គានុរក្សថ្នាក់លេខ២ **អ៊ិច សុផានី** អនុប្រធានការិយាល័យ នៃពន្ធនាគារខេត្តកោះកុង

២-លោកវរអគ្គានុរក្សថ្នាក់លេខ២ **ណុប សេខ** អនុប្រធានការិយាល័យ នៃពន្ធនាគារខេត្តកោះកុង

៣-លោកស្រីវរអគ្គានុរក្សថ្នាក់លេខ២ **ម៉ា សុផល** អនុប្រធានការិយាល័យ នៃពន្ធនាគារខេត្តកោះកុង ។

**ខ- មេដាយប្រាក់ការងារ**

១-លោកវរអគ្គានុរក្សថ្នាក់លេខ២ **ហែម ម៉ាន់នី** អនុប្រធានការិយាល័យ នៃពន្ធនាគារខេត្តកោះកុង

២-លោកវរអគ្គានុរក្សថ្នាក់លេខ៣ **ឃឹម ខេន** ប្រធានផ្នែកសុខាភិបាល នៃពន្ធនាគារខេត្តកោះកុង

៣-លោកអគ្គានុរក្សថ្នាក់លេខ១ **អូន ចិន្តា** ប្រធានផ្នែកអគ្គានុរក្ស នៃពន្ធនាគារខេត្តកោះកុង ។

**គ- មេដាយសំរឹទ្ធការងារ**

១-លោកអគ្គានុរក្សថ្នាក់លេខ១ **លី ឌុទ្ធី** ប្រធានផ្នែកកស្តុភារ នៃពន្ធនាគារខេត្តកោះកុង

២-លោកស្រីអនុរក្សថ្នាក់លេខ៣ **អៀង ពុធនីភា** មន្ត្រីផ្នែករដ្ឋបាល នៃពន្ធនាគារខេត្តកោះកុង

៣-លោកអនុរក្សថ្នាក់លេខ៣ **អួន ដានីន** មន្ត្រីផ្នែកអប់រំកែប្រែ នៃពន្ធនាគារខេត្តកោះកុង ។

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ២*
*-រាជកិច្ច*
*-ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០៤០ អនក្រ.បក

### អនុក្រឹត្យ
### ស្តីពី
### ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

### សម្រេច

**មាត្រា ១ .-** ដាក់លោកស្រី **ឆាយ សៀកលី** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ៣ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាប្រធាននាយកដ្ឋាន នៅក្រសួងធម្មការ និងសាសនា ឱ្យចូលនិវត្តន៍មុនអាយុកំណត់ តាមការស្នើសុំរបស់សាមីខ្លួន ចាប់ពីថ្ងៃទី ០១ ខែ **វិច្ឆិកា** ឆ្នាំ **២០១៦** តទៅ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ [illegible] ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១០៥១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិមន្ត្រីនគរបាលជាតិកម្ពុជា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១ :** តម្លើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- វរសេនីយ៍ទោ **គិន ម៉ារី** អត្តលេខ ០៥០៧៦

២- វរសេនីយ៍ទោ **សឿន សឿង** អត្តលេខ ៥៥០៥៧ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០២២ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងលោក **ចែម គីនរីមឧត្តី** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៤ ឲ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា                ជាតិ   សាសនា   ព្រះមហាក្សត្រ

លេខៈ...១០៤៣...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងលោក **សុខា វ៉ាម** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៤ ឲ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលស្រុករំដួល ខេត្តស្វាយរៀង។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១០៧៤...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈ អភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងលោក **ស៊ិត ម៉ុនស៊ិន** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៣ ឲ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលស្រុកស្វាយលើ នៃខេត្តសៀមរាប សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ៩ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១០៧៥ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈ អភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងលោក **ហាក់ ម៉ុងហួត** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៤ ឲ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលស្រុកបារាយណ៍ នៃខេត្តកំពង់ធំ សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១០២៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.**_បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ១៧គ្រឿង ប្រគេន និងជូនសប្បុរសជន ដែលបានបរិច្ចាគបច្ច័យ និងធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅវត្តទេពពោធិវង្ស (ហៅវត្តថ្មី) សង្កាត់គោកចក និងព្រះវិហារ នៅវត្តមុន្នីចេស្តា(ហៅវត្តពោធិពីរដើម) សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កន្លងមក ដូចមានរាយព្រះនាម និងនាមខាងក្រោម៖

**ក-មេដាយមាសស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១- | លោក | **ស៊ូរ ឆ្លាតុខ** | អភិបាលក្រុងសៀមរាប ថវិកា ១៣.០០០ ដុល្លារ |
| ២- | ឧបាសក | **សេខ គីមអឿន** | គណៈកម្មការវត្តមុនីចេស្តា ថវិកា ១២.០០០ ដុល្លារ |

**ខ-មេដាយសំរឹទ្ធស្ថាបនាជាតិ**

| | | | | |
|---|---|---|---|---|
| ១- | ព្រះតេជគុណអគ្គជាតោ | **ម៉េខ ចាន់ធូច** | ព្រះគ្រូសូត្រឆ្វេងវត្តមុន្នីចេស្តា | បច្ច័យ ២.៣០០ ដុល្លារ |
| ២- | ព្រះតេជគុណអគ្គទិន្នោ | **គីម តាំងលី** | ព្រះសូត្រវត្តមុន្នីចេស្តា | បច្ច័យ ២.១០០ ដុល្លារ |
| ៣- | ឧបាសក | **ទិត ឃ្លាំង** | អាចារ្យវត្តមុន្នីចេស្តា | ថវិកា ២.០០០ ដុល្លារ |
| ៤- | ឧបាសក | **សោម ញាណ** | អាចារ្យវត្តមុន្នីចេស្តា | ថវិកា ១.៨០០ ដុល្លារ |
| ៥- | លោក | **ឆែម សារិន** | ប្រធានគណៈកម្មការសាងសង់វត្តមុន្នីចេស្តា | ថវិកា ១.៨០០ ដុល្លារ |
| ៦- | ឧបាសិកា | **ឯម ណារី** | សប្បុរសជននៅខេត្តសៀមរាប | ថវិកា ១.៧០០ ដុល្លារ |
| ៧- | លោក | **ស ពន្លឺ** | ជាងកសាងព្រះវិហារ | ថវិកា ១.៧០០ ដុល្លារ |
| ៨- | លោក | **ខៀវ សត** | ចៅសង្កាត់ស្លក្រាម | ថវិកា ១.៦០០ ដុល្លារ |

| | | | |
|---|---|---|---|
| ៩- | លោក | **ញឹក សុផល** | មេប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ស្លក្រាម ថវិកា ១.៥៥០ ដុល្លារ |
| ១០- | ឧបាសិកា | **ទូច រស់** | សប្បុរសជននៅខេត្តសៀមរាប ថវិកា ១.៥០០ ដុល្លារ |
| ១១- | ឧបាសិកា | **ជី សុន** | សប្បុរសជននៅខេត្តសៀមរាប ថវិកា ១.៥០០ ដុល្លារ |
| ១២- | អ្នកស្រី | **ស្រី រ័ត្ន** | សប្បុរសជននៅខេត្តសៀមរាប ថវិកា ១.៥០០ ដុល្លារ |
| ១៣- | លោក | **សៀ្វ ណារ៉េន** | សប្បុរសជននៅខេត្តសៀមរាប ថវិកា ១.៥០០ ដុល្លារ |
| ១៤- | លោក | **ម៉ែន សំអាត** | សប្បុរសជននៅខេត្តសៀមរាប ថវិកា ១.៤០០ ដុល្លារ |
| ១៥- | លោក | **កែវ ភន** | សប្បុរសជននៅខេត្តសៀមរាប ថវិកា ១.២០០ ដុល្លារ |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១០៤៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.**-បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជនចំនួន ៣៨រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងអភិវឌ្ឍន៍មូលដ្ឋានលើគ្រប់វិស័យស្ថិតនៅក្នុង ស្រុកសង្កែ ខេត្តបាត់ដំបង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

| | | |
|---|---|---|
| ព្រះតេជគុណ | **គ្រួច តាដ** | អនុគណស្រុកសង្កែ |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

| | | |
|---|---|---|
| ១ -ព្រះតេជគុណ | **ចិន ជេត** | វិន័យធរអនុគណស្រុកសង្កែ |
| ២ -ព្រះតេជគុណ | **ដែន សឿត** | ធម្មធរអនុគណស្រុកសង្កែ |
| ៣ -ព្រះតេជគុណ | **សេខ រុន** | សមុហ៍អនុគណស្រុកសង្កែ |
| ៤ -ព្រះតេជគុណ | **ឌុខ ហ៊ាត** | លេខាធិការអនុគណស្រុកសង្កែ |

**គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ**

| | | |
|---|---|---|
| ១ -ព្រះតេជគុណ | **ម៉ាន់ ចិន្តា** | ព្រះចៅអធិការវត្តតាមិម |
| ២ -ព្រះតេជគុណ | **សៀង សាន** | ព្រះចៅអធិការវត្តបាឡាត់ |
| ៣ -ព្រះតេជគុណ | **លន់ រ៉ែម** | ព្រះចៅអធិការវត្តសន្តិវ័ន |
| ៤ -ព្រះតេជគុណ | **សួង សែត** | ព្រះចៅអធិការវត្តជោតិក |
| ៥ -ព្រះតេជគុណ | **ម៉ុម ហេង** | ព្រះចៅអធិការវត្តការស្នឺ |
| ៦ -ព្រះតេជគុណ | **ហែម ណារិទ្ធ** | ព្រះចៅអធិការវត្តឬទ្ធមុខ |
| ៧ -ព្រះតេជគុណ | **នែម ឈឿន** | ព្រះចៅអធិការវត្តជម្ពូព្រឹក្ស |

| | | |
|---|---|---|
| ៨ -ព្រះតេជគុណ | **ឆាយ ខុន** | ព្រះចៅអធិការវត្តបឹងទឹម |
| ៩ -ព្រះតេជគុណ | **ផល អេខ** | ព្រះចៅអធិការវត្តបឹងឈូក |
| ១០ -ព្រះតេជគុណ | **ហ៊ីង ចាន់** | ព្រះចៅអធិការវត្តស្តក្រោម |
| ១១ -ព្រះតេជគុណ | **មាច ម៉ម** | ព្រះចៅអធិការវត្តប្រឡាយថ្លូវ |
| ១២ -ព្រះតេជគុណ | **ភឿក ម៉ៃ** | ព្រះចៅអធិការវត្តបញ្ញា |
| ១៣ -ព្រះតេជគុណ | **អ៊ុយ ដុង** | ព្រះចៅអធិការវត្តកំពង់គោ |
| ១៤ -ព្រះតេជគុណ | **អេ វ៉ាវ** | ព្រះចៅអធិការវត្តបុះបេង |
| ១៥ -ព្រះតេជគុណ | **អ៊ិត លឿម** | ព្រះចៅអធិការវត្តសិរីបួខ្មារ |
| ១៦ -ព្រះតេជគុណ | **សំ ផាន់យ៉ា** | ព្រះចៅអធិការវត្តស្វាយកង់ |
| ១៧ -ព្រះតេជគុណ | **ចាន់ សុជាតិ** | ព្រះចៅអធិការវត្តអន្លង់វិល |
| ១៨ -ព្រះតេជគុណ | **យឿន យ៉ុន** | ព្រះចៅអធិការវត្តដំបូកបុណ្យ |
| ១៩ -ព្រះតេជគុណ | **ចែង សឿន** | ព្រះចៅអធិការវត្តដំណាក់រទេះ |
| ២០ -ព្រះតេជគុណ | **ផាន់ ជា** | ព្រះចៅអធិការវត្តព្រៃស្វាយ |
| ២១ -ព្រះតេជគុណ | **ម៉ែន សារឿន** | ព្រះចៅអធិការវត្តកណ្តាល |
| ២២ -ព្រះតេជគុណ | **មាន ចក់** | ព្រះចៅអធិការវត្តទួលស្នួល |
| ២៣ -ព្រះតេជគុណ | **ម៉ៅ ព្រឹម** | ព្រះចៅអធិការវត្តបាសែត |
| ២៤ -ព្រះតេជគុណ | **ជាន នៅ** | ព្រះចៅអធិការវត្តសម្តេច |
| ២៥ -ព្រះតេជគុណ | **រ៉ូ សារឿប** | ព្រះចៅអធិការវត្តកំណប់ |
| ២៦ -ព្រះតេជគុណ | **យ៉ុន ថៃ** | ព្រះចៅអធិការវត្តព្រៃរកា |
| ២៧ -ព្រះតេជគុណ | **គង់ ស៊ីមាន** | ព្រះចៅអធិការវត្តថែង |
| ២៨ -ព្រះតេជគុណ | **ស្ងួន ស្រេង** | ព្រះចៅអធិការវត្តកំពង់អំពិល |
| ២៩ -ព្រះតេជគុណ | **រិន ហ្វត** | ព្រះចៅអធិការវត្តនរា |
| ៣០ -ព្រះតេជគុណ | **ផ្លុង ភ្លី** | ព្រះចៅអធិការវត្តអណ្តូងត្នោត |
| ៣១ -ព្រះតេជគុណ | **ផុង សាវេត** | ព្រះចៅអធិការវត្តទួលពន្លៃ |
| ៣២ -ព្រះតេជគុណ | **វ៉ាត់ វណ្ណធីន** | គង់នៅវត្តស្វាយ |
| ៣៣ -លោកស្រី | **សង់ វីដែត** | អនុប្រធានមណ្ឌលសុខភាពឃុំអន្លង់វិល |

**មាត្រា ២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗ ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។៚

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ តុលា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..១០៧៤...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១**.-បំពាក់  **មេដាយការងារ** ចំនួន ០៧ គ្រឿងតាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការចំនួន ៧រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយប្រាក់ការងារ**

| | | |
|---|---|---|
| ១-លោក | **សូ  សារិទ្ធ** | បុគ្គលិកមណ្ឌលសុខភាពឃុំអន្លង់វិល |

**ខ-មេដាយសំរិទ្ធការងារ**

| | | |
|---|---|---|
| ១-លោក | **គីម  ម៉ុនណាត** | បុគ្គលិកមណ្ឌលសុខភាពឃុំអន្លង់វិល |
| ២-លោក | **យឿត សុភ័ណ្ឌា** | បុគ្គលិកមណ្ឌលសុខភាពឃុំអន្លង់វិល |
| ៣-លោក | **ហ៊ុយ  សុធារះ** | បុគ្គលិកមណ្ឌលសុខភាពឃុំអន្លង់វិល |
| ៤-លោក | **ចាន់  ម៉ុនឡេខ** | បុគ្គលិកមណ្ឌលសុខភាពឃុំអន្លង់វិល |
| ៥-លោកស្រី | **នូ  វ៉ាន្នី** | បុគ្គលិកមណ្ឌលសុខភាពឃុំអន្លង់វិល |
| ៦-កញ្ញា | **វឿន  សុខណ្ណាពណ្ណារាយ** | បុគ្គលិកមណ្ឌលសុខភាពឃុំអន្លង់វិល |

**មាត្រា ២.**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗ ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។៚

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែ កញ្ញា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ :** ១០៧៥ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

## សម្រេច

**មាត្រា១.**. បំពាក់មេដាយមាសស្ថាបនាជាតិ ជូនម្ចាស់ជំនួយជប៉ុន ចំនួន៧រូប ដែលបានផ្តល់អំណោយកង់ដល់កុមារកំព្រា និងសិស្សានុសិស្សក្រីក្រនៅកម្ពុជា ចាប់តាំងពីឆ្នាំ ២០០៩ រហូតមកដល់ពេលបច្ចុប្បន្ន ដែលមានកង់សរុបចំនួន ១៥.២៥០ គ្រឿង គិតជាទឹកប្រាក់ ចំនួន ៧៨.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-លោក | **ម៉ាសាហ៊ីរ៉ូ សាណូ** | ( Masahiro SANO ) | ប្រធានអង្គការកុគីសៃ |
| ២-លោក | **ណូរិអូ តាកាណូ** | ( Norio Takano ) | ម្ចាស់ជំនួយ |
| ៣-លោក | **តាកាអាគិ យ៉ាម៉ាស្សាគិ** | ( Takaaki Yamazaki ) | ម្ចាស់ជំនួយ |
| ៤-លោក | **គូអ៊ិឈិ ម៉ារីយ៉ាម៉ា** | ( Kouichi Maruyama ) | ម្ចាស់ជំនួយ |
| ៥-លោក | **ចូអ៊ិឈិ អ៊ិស៊ិហ្សាកា** | ( Jyoichi Ishizaka ) | ម្ចាស់ជំនួយ |
| ៦-លោក | **វ៉ាំងសង់ ដារ៉ូ** | ( Vincent DAREAU ) | ប្រធានអង្គការកុមារអាស៊ី |
| ៧-លោក | **ពិន សារ៉ាវេត** | ( PIN Saraveth ) | ប្រធានរដ្ឋបាល |

**មាត្រា២.**. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៣ សសរ

## សេចក្តីសម្រេច

## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនសម្តេច ក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជំនួសសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចូលរួមកិច្ចប្រជុំកំពូលកិច្ចសន្ទនានៃកិច្ចសហប្រតិបត្តិការអាស៊ីលើកទី២ នៅទីក្រុងបាងកក ចាប់ពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៦ រហូតដល់ពេលសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន អភិបាលរាជធានី អភិបាលគ្រប់ខេត្ត និងសម្តេចក្រឡាហោម **ស ខេង** ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:..១១៤...សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការជ្រើសរើសពលទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**ប្រការ១ :** អនុញ្ញាតឲ្យក្រសួងការពារជាតិជ្រើសរើសពលទាហាន ចំនួន ១៣០(មួយរយសាមសិប)នាក់ សម្រាប់បំពេញក្របខ័ណ្ឌឲ្យអង្គភាពវិស្វកម្ម កងឯកភាពអង្គរក្ស សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ចំណុះនាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ ។

**ប្រការ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១៥ សសរ

## សេចក្តីសម្រេច

## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវអញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា ទៅចូលរួមកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម លើកទី៨ (8th CLMV) កិច្ចប្រជុំកំពូលយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាយេយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ លើកទី៧ (7th ACMECS) និងវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីមេគង្គ (WEF-Mekong) នៅទីក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១៦ រហូតដល់ពេលសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន អភិបាលរាជធានី អភិបាលគ្រប់ខេត្ត និងសម្តេចក្រឡាហោម **ស ខេង** ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ តុលា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:១៦៦ សសរ**

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំកិច្ចប្រជុំវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ាន ឆ្នាំ២០១៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- លិខិតលេខ ៧០៧ សជណ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំកិច្ចប្រជុំវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ាន ឆ្នាំ២០១៧ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ស៊ុន ចាន់ថុល** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | ប្រធាន |
| ២- ឯកឧត្តម **ប៉ាន សូរស័ក្តិ** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣- ឯកឧត្តម **តៅ គឹមហួន** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៤- ឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥- លោក **សែន សិលា** | ទីប្រឹក្សាផ្ទាល់**សម្តេចតេជោនាយករដ្ឋមន្ត្រី** | សមាជិក |

៦- ឯកឧត្តម នាយឧត្តមសេនីយ៍ **ឯម សំអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៧- ឯកឧត្តម នាយឧត្តមសេនីយ៍ **ម៉ឺង សំផន** រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

៨- ឯកឧត្តម **លុយ ដាវីត** រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៩- ឯកឧត្តម **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ជាអនុប្រធានប្រចាំការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិសមាជិក

១០- ឯកឧត្តម **ហេង សុខគង់** រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម សមាជិក

១១- ឯកឧត្តម **ជា ច័ន្ទបរិបូរណ៍** រដ្ឋលេខាធិការក្រសួងព័ត៌មាន សមាជិក

១២- ឯកឧត្តម **ទិត ចន្ថា** រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

១៣- ឯកឧត្តម **ជូ យិនស៊ីម** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

១៤- លោកជំទាវ **ម៉ិញ ភុសនី** រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក

១៥- ឯកឧត្តម **ទី សុគន្ធ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសមាជិក

១៦- លោកជំទាវ **គឹម សេដ្ឋានី** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១៧- លោកជំទាវ **សេង វណ្ណាសាយ** រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម សមាជិក

១៨- ឯកឧត្តម **សុខ ខាវ៉ាន់** រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល សមាជិក

១៩- ឯកឧត្តម **ភាន ចាន់មេត្តា** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក

២០- ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក

២១- ឯកឧត្តម នាយឧត្តមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ សមាជិក

២២- ឯកឧត្តម នាយឧត្តមសេនីយ៍ **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

២៣- ឯកឧត្តម **ជា វុទ្ធី** អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា សមាជិក

២៤- ឯកឧត្តម **ស៊ុំ ម៉ាប់** អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា សមាជិក

២៥- ឯកឧត្តម **អ៊ិង សុផល្លែត** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក

២៦- ឯកឧត្តម **ប៉ា សុជាតិវង្ស** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ សមាជិក

២៧- ឯកឧត្តម **ឃឹម ប៊ុនសុខ** អភិបាលនៃគណៈអភិបាលខេត្តសៀមរាប សមាជិក

២៨- ឯកឧត្តម **កែវ សិរីបុត្រ** អគ្គលេខាធិការរង គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សមាជិក

២៩- ឯកឧត្តម **ហ៊ុន ម៉ានី** ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា(ស.ស.យ.ក)សមាជិក

**ប្រការ២ ..**

គណៈកម្មការអន្តរក្រសួងរៀបចំកិច្ចប្រជុំវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ាន ឆ្នាំ២០១៧ មានភារកិច្ចដឹកនាំ ចាត់ចែង និងត្រួតពិនិត្យដំណើរការរៀបចំកិច្ចប្រជុំវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ានឆ្នាំ ២០១៧ ឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ។ គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតលេខាធិការដ្ឋាន អនុគណៈកម្មការ ឬក្រុមការងារបន្ថែម តាមការចាំបាច់។

គណៈកម្មការអន្តរក្រសួងនេះ អាចអញ្ជើញតំណាងក្រសួង-ស្ថាប័ន វិស័យឯកជន ឥស្សរជនជាតិ-អន្តរជាតិ ឬភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីពិគ្រោះយោបល់ ឬចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ឬចូលរួមក្នុងការងារសិក្សាស្រាវជ្រាវ និងផ្តល់យោបល់ តាមការចាំបាច់។

**ប្រការ៣ .-**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ថវិកាដោយឡែករបស់ក្រសួងសាធារណការនិងដឹកជញ្ជូន និងប្រភពថវិកាស្របច្បាប់ផ្សេងៗទៀត ដើម្បីដំណើរការការងាររបស់ខ្លួន។ គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិស្វែងរកដៃគូអភិវឌ្ឍន៍ ឬផ្នែកឯកជន ដើម្បីជួយទ្រទ្រង់និងឧបត្ថម្ភដល់ដំណើរការរៀបចំកិច្ចប្រជុំវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ាន ឆ្នាំ២០១៧នេះ។

**ប្រការ៤ .-**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រា និងក្បាលលិខិតដែលមានសញ្ញាសម្គាល់របស់ក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីដំណើរការការងាររបស់ខ្លួនតាមការចាំបាច់។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ៗ៧ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១១២៧ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការតព្វកិច្ចសារពើពន្ធ
## ចំពោះសហគ្រាសដែលអនុវត្តពហុគម្រោង

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា1
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់ក្នុងការងារគ្រប់គ្រងប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះមានគោលបំណងកំណត់កាតព្វកិច្ចសារពើពន្ធ ចំពោះសហគ្រាសនីតិបុគ្គលណាមួយ ដែលអនុវត្តពហុគម្រោង (សកម្មភាពអាជីវកម្មច្រើន) ហើយទទួលបានរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញខុសៗគ្នា និង/ឬជាប់ពន្ធលើប្រាក់ចំណេញតាមអត្រាខុសៗគ្នា ស្របតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិស្តីពីវិនិយោគ។

**ប្រការ ២.- វិសាលភាព**

ប្រកាសនេះមានវិសាលភាពចំពោះសហគ្រាសនីតិបុគ្គលណាមួយ ដែលអនុវត្ត៖

- ពហុគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ (គ.ល.គ)
- ពហុគម្រោងមិនមែន គ.ល.គ ដែលត្រូវជាប់ពន្ធលើប្រាក់ចំណេញតាមអត្រាខុសៗគ្នា
- គម្រោង គ.ល.គ ផង និងមិនមែន គ.ល.គ ផង។

ប្រកាសនេះមិនត្រូវអនុវត្តចំពោះ៖

- ពហុគម្រោង គ.ល.គ ដែលទទួលបានរយៈពេលចាប់ផ្តើម និងបញ្ចប់ការលើកលែងពន្ធលើប្រាក់ចំណេញដូចគ្នា និងជាប់ពន្ធលើប្រាក់ចំណេញតាមអត្រាដូចគ្នា
- ពហុគម្រោងមិនមែន គ.ល.គ ដែលត្រូវជាប់ពន្ធលើប្រាក់ចំណេញតាមអត្រាដូចគ្នា
- ពហុគម្រោងដែលចុះបញ្ជីពន្ធដារជាសហគ្រាសនីតិបុគ្គលផ្សេងៗគ្នា។

**ប្រការ ៣.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ ពាក្យ៖

១- **"ពហុគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ហៅកាត់ ពហុគម្រោង គ.ល.គ"** សំដៅដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់លើសពីមួយឡើងទៅ ទទួលបានរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញខុសៗគ្នា ឬជាប់ពន្ធលើប្រាក់ចំណេញតាមអត្រាខុសៗគ្នា អនុវត្តដោយសហគ្រាសនីតិបុគ្គលណាមួយ។

២- **"ពហុគម្រោងមិនមែន គ.ល.គ"** សំដៅដល់សកម្មភាពអាជីវកម្មច្រើនដែលមិនមែនជាគម្រោង គ.ល.គ។

៣- **"ចំណូលបន្ទាប់បន្សំរបស់សហគ្រាស"** មិនត្រូវបានចាត់ទុកថាជាគម្រោងដោយឡែករបស់សហគ្រាសឡើយ។ ចំណូលបន្ទាប់បន្សំមានជាអាទិ៍ ចំណូលពីអចលនទ្រព្យ ចំណូលពីមូលបត្រ និងភាគហ៊ុន ចំណូលពីឥណទេយ្យ ប្រាក់ធានា គណនីសន្សំ គណនីចរន្ត សួយសារ ចំណូលពីភាគលាភ អំណោយនិងឧបត្ថម្ភកធន និងចំណូលបន្ទាប់បន្សំប្រហាក់ប្រហែលដទៃទៀត ដូចមានចែងក្នុងផ្នែក ៤.៩ និងផ្នែក ៤.១០ នៃប្រកាសលេខ ១០៥៩ សហវ. ប្រក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់ចំណេញ។

**ប្រការ ៤.- ការចុះបញ្ជី និងការផ្តល់លេខអត្តសញ្ញាណកម្មសារពើពន្ធ**

ដូចមានចែងក្នុងមាត្រា៣ ថ្មី និងមាត្រា១០១ នៃច្បាប់ស្តីពីសារពើពន្ធ និងមាត្រា៥.៤ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់គោលដៅពន្ធដារ÷

១- សហគ្រាសនីតិបុគ្គលណាមួយដែលអនុវត្តពហុគម្រោង គ.ល.គ ឬអនុវត្តគម្រោង គ.ល.គ ផង និងមិនមែន គ.ល.គ ផង ឬពហុគម្រោងមិនមែន គ.ល.គ ត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ និងត្រូវបានផ្តល់លេខអត្តសញ្ញាណកម្មសារពើពន្ធដោយឡែកៗពីគ្នា។

២- គម្រោង គ.ល.គ នីមួយៗ ឬគម្រោងមិនមែន គ.ល.គ នីមួយៗ ត្រូវបានចាត់ទុកជាអ្នកជាប់ពន្ធមួយដោយឡែកៗពីគ្នា។

**ប្រការ ៥.- ភាតព្វកិច្ចសារពើពន្ធ និងកិច្ចបញ្ជិកាគណនេយ្យរបស់សហគ្រាស**

សហគ្រាសនីតិបុគ្គលណាមួយដែលអនុវត្តពហុគម្រោង គ.ល.គ ឬអនុវត្តគម្រោង គ.ល.គ ផង និងមិនមែន គ.ល.គ ផង ឬពហុគម្រោងមិនមែន គ.ល.គ ដូចមានចែងក្នុងកថាខណ្ឌ១ នៃប្រការ៤ ខាងលើ ត្រូវ÷

១- ស្នើសុំចុះបញ្ជី និងប្រកាសបង់ពន្ធប៉ាតង់សម្រាប់គម្រោងនីមួយៗនៅរដ្ឋបាលសារពើពន្ធ ក្នុងអំឡុងពេល ១៥ថ្ងៃ ក្រោយគម្រោងនីមួយៗធ្វើសកម្មភាពសេដ្ឋកិច្ច។

២- ញែកដាច់ពីគ្នាដើមទុនវិនិយោគ ទ្រព្យសកម្ម ទ្រព្យអកម្ម បុគ្គលិក-កម្មករ អ្នកគ្រប់គ្រង និងព័ត៌មានហិរញ្ញវត្ថុផ្សេងៗសម្រាប់បម្រើឱ្យគម្រោងនីមួយៗ។

៣- កាន់កាប់និងកត់ត្រាបញ្ជិកាគណនេយ្យ និងត្រូវបែងចែកឱ្យបានត្រឹមត្រូវនូវចំណូល និងចំណាយ ដែលកើតឡើងដោយឡែកៗពីគ្នាសម្រាប់គម្រោងនីមួយៗ។

៤- ចំពោះចំណូល និងចំណាយដែលមិនអាចបែងចែកដាច់ដោយឡែកពីគ្នាតាមគម្រោងនីមួយៗ សហគ្រាសត្រូវធ្វើការបែងចែកតាមគោលការណ៍សមាមាត្រ ដោយយកផលរបរជាគោលធៀបនឹងចំណាយ។ ក្នុងករណីទាក់ទិននឹងគម្រោងដែលមិនទាន់មានផលរបរ សហគ្រាសត្រូវបែងចែកតាមសមាមាត្រទំហំនៃការប្រើប្រាស់ទ្រព្យសកម្ម ឬទំហំនៃចំណាយទាំងនោះ។ ចំណាយសមាមាត្រទាំងនោះ រួមមាន ចំណាយរដ្ឋបាលរួម ចំណាយជួលការិយាល័យរួម ប្រាក់បៀវត្សអ្នកគ្រប់គ្រង ឬបុគ្គលិកទទួលខុសត្រូវរួម និងចំណាយផ្សេងៗទៀតសម្រាប់បំរើសកម្មភាពច្រើនជាងមួយគម្រោង។

៥- កាន់កាប់ កត់ត្រា និងរក្សាបញ្ជីស្តុកទំនិញ ផលិតផលសម្រេច ផលិតផលពាក់កណ្តាលសម្រេច វត្ថុធាតុដើម និងសម្ភារៈផ្គត់ផ្គង់ផ្សេងៗគ្នាសម្រាប់គម្រោងនីមួយៗដាច់ដោយឡែកពីគ្នា។

៦- ចំពោះទ្រព្យសកម្មរយៈពេលវែងដែលមិនអាចធ្វើការបែងចែកបាន ហើយត្រូវបានប្រើប្រាស់លាយឡំគ្នា សហគ្រាសត្រូវកត់ត្រាតាមដាន និងធ្វើរំលស់នៃទ្រព្យទាំងនោះនៅក្នុងគម្រោងដែលទ្រព្យសកម្មនោះត្រូវបានកត់ត្រាដំបូង ហើយត្រូវធ្វើការបែងចែកចំណាយទាយជ្ជទាន

ឱ្យដល់រំលស់នៃទ្រព្យទាំងនោះទៅតាមសមាមាត្រនៃផលរបរ ឬទំហំនៃការប្រើប្រាស់ ក្នុងករណីទាក់ទិនទៅនឹងគម្រោងដែលមិនទាន់មានផលរបរ។

